# របៀបដែលខ្ញុំទទួលពិធីបុណ្យជ្រមុជទឹក















ជម្រាបសួរ ! ខ្ញុំឈ្មោះ អារ៉ាណូអារីអ៊ី ។ ខ្ញុំរស់នៅក្នុងប្រទេសតាហ៊ីទី ។ ខ្ញុំមានអាយុ ១១ឆ្នាំ ហើយខ្ញុំមានមោទនភាពដែលនិយាយថាខ្ញុំជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

## តើអ្នកបានរៀនអំពីសាសនាចក្រដោយរបៀបណា ?

មិត្តភក្តិមួយចំនួនបានអញ្ជើញគ្រួសារខ្ញុំទៅសកម្មភាពសាសនាចក្រមួយ ។ យើងក៏ត្រូវបានអញ្ជើញឲ្យទៅចូលរួមពិធីបុណ្យជ្រមុជទឹករបស់កុមារម្នាក់ផងដែរ ។ ខ្ញុំបានសុំម្ដាយរបស់ខ្ញុំថា តើខ្ញុំអាចជួបជាមួយពួកអ្នកផ្សព្វផ្សាយសាសនាបានឬទេ ពីព្រោះខ្ញុំពិតជាចង់រៀនបន្ថែមទៀតអំពីព្រះយេស៊ូវគ្រីស្ទ ។

## តើការជួបជាមួយអ្នកផ្សព្វផ្សាយសាសនាមានលក្ខណៈបែបណាដែរ ?

ពួកអ្នកផ្សព្វផ្សាយសាសនាចិត្តល្អណាស់ ! ខ្ញុំតែងតែរំភើបចិត្តក្នុងការរៀនមេរៀនជាមួយពួកគាត់អំពីព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ ។ ខ្ញុំចូលចិត្តដំណើររឿងដែលពួកគាត់បានប្រាប់ខ្ញុំ និងល្បែងដែលយើងបានលេងដើម្បីជួយបង្រៀនខ្ញុំ ។



## តើពិធីបុណ្យជ្រមុជទឹករបស់អ្នកមានលក្ខណៈដូចម្ដេច ?

ប៉ារបស់ខ្ញុំបានជ្រមុជទឹកឲ្យម៉ាក់ខ្ញុំ និងខ្ញុំនៅថ្ងៃខួបកំណើតអាយុ ១១ ឆ្នាំរបស់ខ្ញុំ ។ ខ្ញុំសប្បាយចិត្តខ្លាំងណាស់ ! យើងបានអញ្ជើញមនុស្សជាទីស្រឡាញ់របស់យើងជាច្រើន ។ មិត្តរួមថ្នាក់ និងគ្រូរបស់ខ្ញុំបានអញ្ជើញមកដើម្បីគាំទ្រខ្ញុំ ។

ពេលខ្ញុំងើបចេញពីទឹក ខ្ញុំបានពោរពេញដោយក្ដីអំណរ ។ ខ្ញុំបានញញឹមយ៉ាងខ្លាំងរហូតដល់គុម្ពត្រចៀក ! ខ្ញុំសប្បាយចិត្តណាស់ដែលខ្ញុំអាចធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទ ។

## តើការទៅអង្គការបឋមសិក្សាលើកដំបូងមានសភាពបែបណាដែរ ?

ដំបូងខ្ញុំភ័យណាស់ ខ្ញុំហៀបនឹងយំ ។ ប៉ុន្តែបន្ទាប់មកខ្ញុំបានទៅចូលរួមសកម្មភាពអង្គការបឋមសិក្សា ។ ខ្ញុំចាប់ផ្ដើមស្គាល់មនុស្សគ្រប់គ្នា ហើយខ្ញុំបានរាប់អានមិត្តភក្តិមួយចំនួន ។

ប្រសិនបើបងប្អូនមកថ្មី ដំបូន្មានរបស់ខ្ញុំគឺថាត្រូវមកអង្គការបឋមសិក្សារបស់បងប្អូនទោះបីជាបងប្អូនភ័យខ្លាចពីដំបូងក៏ដោយ ។ យើងស្រឡាញ់មនុស្សមកថ្មី !

## តើអ្នកធ្វើតាមព្រះយេស៊ូវតាមរបៀបណា ?

ខ្ញុំអធិស្ឋាន ហើយទៅព្រះវិហារជារៀងរាល់ថ្ងៃអាទិត្យ ។ ខ្ញុំនិយាយជាមួយមិត្តភក្តិរបស់ខ្ញុំ អំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។

ខ្ញុំព្យាយាមស្វែងរកអ្នកដទៃដែលត្រូវការជំនួយ ។ នៅផ្ទះខ្ញុំជួយកិច្ចការផ្ទះម៉ាក់របស់ខ្ញុំ ។ ខ្ញុំជួយថែសួនច្បារប៉ា កាប់អុស និងសាងសង់របស់របរ ។ កាលពីរបីខែកន្លងទៅ វួដរបស់យើងមានកម្មវិធីបង្ហាញទេពកោសល្យ ។ ខ្ញុំជាតន្ត្រីករ ដូច្នេះខ្ញុំត្រូវលេងស្គរពេញមួយយប់ !

តើ *អ្នក* ចូលចិត្តអ្វីខ្លះអំពីការជ្រមុជទឹករបស់អ្នក ? ឬតើអ្នកមានចិត្តអន្ទះសាចំពោះអ្វីជាងគេ ?